# អារម្ភកថា

៙៙❖៚៚

រាជរដ្ឋាភិបាលកម្ពុជា បានមើលឃើញយ៉ាងច្បាស់ ប្រកបដោយទស្សនៈវិស័យវែងឆ្ងាយ អំពីសារៈសំខាន់នៃការងារគ្រប់គ្រងបំណុលសាធារណៈ និង បានទទួលស្គាល់ថា កិច្ចការគ្រប់គ្រងបំណុលសាធារណៈ គឺជាសមាសភាគគន្លឹះមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្នុងរយៈពេលកន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់នូវវិធានការចាំបាច់នានា ប្រកបដោយប្រសិទ្ធភាពខ្ពស់ សំដៅពង្រឹងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព ។ វិធានការទាំងនោះ ត្រូវបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុវត្តបានយ៉ាងខ្ជាប់ខ្ជួន ឥតមានរវាត ដែលធ្វើឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពរក្សាបាននូវស្ថិរភាពនៃការគ្រប់គ្រងថវិកា និងម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈកាលជាងពីរទសវត្សរ៍កន្លងមកនេះ ។

កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃកិច្ចអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន គឺការបង្កើនទុនយ៉ាងគំហុកសម្រាប់បម្រើឱ្យការវិនិយោគលើវិស័យអាទិភាពគន្លឹះនានារបស់រាជរដ្ឋាភិបាល ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងទ្រទ្រង់ចីរភាពកំណើន ។ ទន្ទឹមនឹងហិរញ្ញប្បទានឥតសំណងកាន់តែរីងស្ងួតទៅ រាជរដ្ឋាភិបាលបានមើលឃើញប្រភពហិរញ្ញប្បទានសក្តានុពលធំៗពីរ សម្រាប់ហិរញ្ញប្បទានមុខចំណាយខាងលើ គឺ (១) ការខ្ចី ដែលរួមមានការខ្ចីពីដៃគូអភិវឌ្ឍន៍ និង ការបោះផ្សាយមូលបត្ររដ្ឋ និង/ឬ សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ និង (២) ការវិនិយោគសាធារណៈពីវិស័យឯកជនលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលតម្រូវឱ្យមានការធានាពីរាជរដ្ឋាភិបាល ដូចជាគម្រោងសាងសង់វារីអគ្គិសនី គម្រោងសាងសង់រោងចក្រផលិតថាមពលអគ្គិសនីដើរដោយធ្យូងថ្ម គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនី និងគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត ។

ការខ្ចីឥណទាន គឺជាការប្រើប្រាស់លុយអនាគតនៅក្នុងពេលបច្ចុប្បន្ន ដែលចាំបាច់ត្រូវមានការគ្រប់គ្រងលើទំហំនិងលក្ខខណ្ឌនៃការខ្ចីឱ្យបានសមស្រប ប្រើប្រាស់ឱ្យចំទិសដៅអាទិភាព និងប្រកបដោយប្រសិទ្ធភាពខ្ពស់ សំដៅបង្កើនផលិតភាពសេដ្ឋកិច្ច និងការទ្រទ្រង់ចីរភាពកំណើនក្នុងរយៈពេលវែង ដើម្បីទាញយកមកវិញនូវកំណើនចំណូលថវិកាជាតិ ។ បទពិសោធន៍កន្លងមក បង្ហាញថា ការធ្លាក់ចូលក្នុងវិបត្តិបំណុលវ័ណ្ឌករបស់ប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន គឺបណ្តាលមកពីការខ្ចីឥណទានលើសពីលទ្ធភាពថវិកា និងទំហំសេដ្ឋកិច្ចរបស់ខ្លួន ហើយខ្ចីសម្រាប់វិស័យ ឬគម្រោងដែលមិនមានផលិតភាពសេដ្ឋកិច្ច ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលយល់ថា នេះជាពេលវេលាដ៏សមស្របដែលកម្ពុជាត្រូវរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ជាលើកដំបូងរបស់ខ្លួន ដើម្បីបន្តតម្រង់ទិសនៃការខ្ចី និងការប្រើប្រាស់ឥណទានឱ្យចំទិសដៅអាទិភាព ប្រកបដោយប្រសិទ្ធភាព និងការ

ទទួលខុសត្រូវខ្ពស់ ។ និយាយបែបនេះ មិនមែនមានន័យថា កន្លងមក រាជរដ្ឋាភិបាលគ្រប់គ្រងបំណុលសាធារណៈ ដោយគ្មានគោលការណ៍ច្បាស់លាស់នោះទេ ។ រាជរដ្ឋាភិបាលតែងបានដាក់ចេញជាបន្តបន្ទាប់នូវ គោលនយោបាយ និងគោលការណ៍ណែនាំគន្លឹះសំខាន់នានា ដើម្បីតម្រង់ទិសក្នុងការខ្ចីឥណទានសម្រាប់វិស័យ និងគម្រោងវិនិយោគសាធារណៈអាទិភាព សំដៅធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ហើយដែលគោលការណ៍គន្លឹះទាំងនោះត្រូវបានដាក់បញ្ចូលក្នុងឯកសារយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈនេះ ។ គោលនយោបាយ និងគោលការណ៍គន្លឹះទាំងនោះ រួមមាន:

(១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ច អាចទ្រាំទ្របាន

(២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទានខ្ពស់

(៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពសំដៅទ្រទ្រង់ចីរភាពកំណើន និងបង្កើនផលិតភាពសេដ្ឋកិច្ច និង

(៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់បំផុត ។

ក្នុងបរិការណ៍បច្ចុប្បន្ន រាជរដ្ឋាភិបាលទទួលស្គាល់ថា ការបន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ សំដៅរក្សាចីរភាពបំណុលក្នុងរយៈពេលវែង គឺជារបៀបវារៈអាទិភាពមួយ ក្នុងចំណោមរបៀបវារៈអាទិភាពនានានៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កាលពីពេលថ្មីនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដែលជាមូលដ្ឋានសម្រាប់ឱ្យមានការរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ និង ឯកសារយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈ សំដៅបន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជាប្រកបដោយចីរភាព ។

យុទ្ធសាស្រ្តនេះ គឺជាឯកសារគោលនយោបាយរយៈពេលមធ្យម និងវែងរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ។ យុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈ នឹងផ្តល់ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយ ដែលដាក់ចេញនូវវិធានការ និងគោលនយោបាយប្រកបដោយវិចារណកម្ម មានភាពអាចជឿទុកចិត្ត និងភាពអាចប៉ាន់ប្រមាណបាន ជាពិសេសការព្យាករណ៍ជាមុននូវបញ្ហាប្រឈម ហានិភ័យ និងបន្ទុកសេវាបំណុល សម្រាប់ជាមូលដ្ឋាននៃការសម្រេចចិត្តពាក់ព័ន្ធនឹងការស្វែងរកទុនហិរញ្ញវត្ថុបំពេញតម្រូវការហិរញ្ញប្បទានលើវិស័យអាទិភាព ដើម្បីបម្រើឱ្យគោលនយោបាយអភិវឌ្ឍន៍ជាតិ ។

ផ្អែកលើជោគជ័យនៃការគ្រប់គ្រងបំណុលសាធារណៈនាពេលកន្លងមក ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្រ្តនេះ ដើម្បីបន្តរក្សាការគ្រប់គ្រងបំណុលសាធារណៈឱ្យមានចីរភាព រាជរដ្ឋាភិបាលសម្រេចកំណត់ទំហំនៃការខ្ចីឥណទានសម្បទានសម្រាប់ឆ្នាំ ២០១១-២០១៨ ត្រឹមរង្វង់ ៤០០ លានអេសដេអ៊ែក្នុងមួយឆ្នាំ តែអាចមានលទ្ធភាពបង្កើនដល់ ៧០០ លានអេសដេអ៊ែក្នុងមួយឆ្នាំ អាស្រ័យតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែង ។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងគ្មានរវាត នូវវិធានការដូចខាងក្រោម:

១- បន្តប្រើប្រាស់ឥណទានសម្បទាន សម្រាប់វិនិយោគមូលធនលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងទ្រទ្រង់ចីរភាពកំណើន រួមមាន ផ្លូវ ស្ពាន ទំនប់ ប្រឡាយ ប្រព័ន្ធស្រោចស្រព អគ្គិសនី កំពង់ផែ ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត សំដៅជំរុញការពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងទ្រទ្រង់ចីរភាពកំណើនក្នុងរយៈពេលវែង ។

២- បន្តពង្រឹងបន្ថែមយន្តការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈឱ្យមានប្រសិទ្ធភាព ដោយត្រូវបន្តដាក់ចេញនូវរាល់បណ្តាលិខិតបទដ្ឋានគតិយុត្តិ គោលការណ៍ និងនីតិវិធីពាក់ព័ន្ធចាំបាច់នានា ជាពិសេស ការបន្តពង្រឹងអនុវត្តនីតិវិធីដែលកំពុងអនុវត្តជាធរមាន ដែលមានដូចជា នីតិវិធីរួមសម្រាប់ការគ្រប់គ្រងរដ្ឋបាល នីតិធីរួមសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីរួមសម្រាប់ការគ្រប់គ្រងលទ្ធកម្មគម្រោងហិរញ្ញប្បទានពីក្រៅប្រទេស សំដៅធានាបង្កើនប្រសិទ្ធភាពនៃចំណាយថវិកាគម្រោង តាមរយៈកិច្ចលទ្ធកម្មប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ។

៣- បន្តរក្សាកម្រិតសម្បទាននៃឥណទានឱ្យបានខ្ពស់ ពោលគឺត្រូវទទួលយកតែឥណទានណាដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ដែលរួមមានកម្រិតអត្រាការប្រាក់ទាប រក្សារយៈពេលសង និងរយៈពេលអនុគ្រោះវែង អនុលោមទៅតាមលក្ខខណ្ឌវិនិច្ឆ័យនៃការអនុវត្តជាអន្តរជាតិ និងស្របទៅនឹងបរិការណ៍សេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០១១-២០១៨ ។

៤- បន្តជំរុញអនុវត្តគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងវិស័យសំខាន់ៗ សំដៅរក្សាចីរភាពកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែងក្នុងរង្វង់ ៦%-៧% ក្នុងមួយឆ្នាំ និង សម្រេចឱ្យបានចំណូលថវិកាជាតិក្នុងរង្វង់ពី ១៣,៥% ទៅ ១៥% នៃ ផសស ដើម្បីឈានទៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងតិចជាង ១% ក្នុងមួយឆ្នាំ ។ ក្នុងន័យនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបន្តខិតខំអនុវត្តគោលនយោបាយ និងគោលការណ៍ណែនាំនានា របស់រាជរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលចំណូលគ្រប់ប្រភេទ ដើម្បីជាគុណប្រយោជន៍នៃថវិកាជាតិ សំដៅធានាស្ថិរភាពនៃការគ្រប់គ្រងថវិកា និងម៉ាក្រូសេដ្ឋកិច្ច ។

៥- បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ដែលតាមនេះ មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយគត់ ក្រោមការប្រទានសិទ្ធិពីនាយករដ្ឋមន្ត្រី ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានា ការសន្យាផ្នែកហិរញ្ញវត្ថុនានា ការឱ្យប្រាក់គេខ្ចីទាំងក្នុងនិងក្រៅប្រទេស និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឬ

ឱ្យប្រាក់គេខ្ចី ឬ ចេញលិខិតធានា ឬ ក៏ធ្វើទង្វើណាផ្សេងៗទៀត ដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោល ដល់ព្រះរាជាណាចក្រកម្ពុជាបានទេ ។

៦- បន្តពង្រឹងការកៀរគរហិរញ្ញប្បទានឥតសំណង និងពីប្រភពហិរញ្ញប្បទានផ្សេងទៀត សម្រាប់បម្រើឱ្យតម្រូវការវិនិយោគសាធារណៈ ។

៧- ពង្រឹងការតាមដានត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ ជាពិសេសហានិភ័យនៃសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk) និងកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការធានារបស់រដ្ឋ និង គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងទ្រទ្រង់ចិរភាពកំណើន ក្នុងរយៈពេលវែង ។

៨- ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សដែលចូលរួមបំពេញកិច្ចការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជរដ្ឋាភិបាលនឹងបន្តតាមដានយ៉ាងយកចិត្តទុកដាក់ លើដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ នេះ ដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការគ្រប់គ្រងបំណុលសាធារណៈមួយប្រកបដោយចិរភាព ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមលើកស្ទួយចិរភាពកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលវែង និងការទ្រទ្រង់វិស័យសង្គមកិច្ច ដើម្បីសមធមិ និង យុត្តិធមិសង្គម ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**